**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:១១៩៩ខ**

# សារលិខិត

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងឱកាសទិវាជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨

- សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ
- សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី
- លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្ស និងបងប្អូនជនរួមជាតិទាំងអស់ជាទីស្នេហា !

ក្នុងនាមរាជរដ្ឋាភិបាលនិងក្នុងនាមខ្ញុំព្រះករុណាខ្ញុំផ្ទាល់ ខ្ញុំសូមសំដែងនូវការអបអរសាទរជាមួយពិភពលោកទាំងមូល ចំពោះការប្រារព្ធទិវាជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងទិវាគ្រុនចាញ់ពិភពលោក ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃពុធ ១១កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨នេះ ក្រោមប្រធានបទ " **ត្រៀមរួចជាស្រេច ចូលរួមលុបបំបាត់ជំងឺគ្រុនចាញ់** "។ ទិវានេះប្រារព្ធឡើងក្នុងគោលបំណងជំរុញ និងបំផុសការយល់ដឹង និងយកចិត្តទុកដាក់កាន់តែខ្ពស់បន្ថែមទៀត ក្នុងការលើកកម្ពស់សុខុមាលភាពសង្គម និងសំដៅរួមចំណែកដល់ការថែរក្សាសុខភាពរបស់ប្រជាពលរដ្ឋ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំព្រះករុណាខ្ញុំ សូមសំដែងនូវការគាំទ្រយ៉ាងពេញទំហឹងចំពោះគ្រប់សកម្មភាពទាំងអស់ដែលបាននិងកំពុងអនុវត្តក្នុងការជំរុញ និងបំផុសការយល់ដឹងជាសាធារណៈឱ្យកាន់តែទូលំទូលាយនៅទូទាំងប្រទេស ពិសេសនៅតាមទីជនបទ ដើម្បីផ្លាស់ប្តូរផ្នត់គំនិត និងទម្លាប់ប្រជាជនក្នុងការប្រតិបត្តិលើការរស់នៅស្អាត។ ពិតណាស់ថា ជំងឺគ្រុនចាញ់មិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់សុខភាព ចំណាយលុយកាក់តាមរយៈការចំណាយដោយផ្ទាល់លើការព្យាបាល ការខាតបង់ការងារ ការបាត់បង់ផលិតភាព និងអាយុជីវិតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កផលប៉ះពាល់ជាអវិជ្ជមានដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរទៀតផង។ តាមទស្សនទាននេះ យើងទាំងអស់គ្នាចាំបាច់ណាស់ត្រូវបន្តយកចិត្តទុកដាក់លើបញ្ហាជំងឺគ្រុនចាញ់ ដោយយើងមិនអាចមើលរំលងបានឡើយ។ ផ្ទុយទៅវិញ ប្រសិនបើប្រជាពលរដ្ឋមានសុខភាពល្អនឹងនាំឱ្យមានជីវភាពរស់នៅល្អប្រសើរ មានលទ្ធភាពខ្ពស់លើការបង្កើនចំណេះដឹង បង្កើនផលិតភាពដែលនឹងនាំមកនូវភាពរីកចម្រើន សេចក្តីថ្លៃថ្នូរ និងសុភមង្គល។ ដូច្នេះ ទិវាគ្រុនចាញ់ក្រោមប្រធានបទ " **ត្រៀមរួចជាស្រេច ចូលរួមលុបបំបាត់ជំងឺគ្រុនចាញ់** " នេះសមស្របនឹងដំណើរវិវត្តិនៃសភាពការណ៍សង្គម-សេដ្ឋកិច្ចរបស់កម្ពុជា ដែលកំពុងពង្រីកការអភិវឌ្ឍតាមព្រំដែន

និងតំបន់អេកូទេសចរធម្មជាតិ ព្រៃភ្នំ ដែលប្រឈមនឹងអត្រាឈឺ ស្លាប់ដោយជំងឺគ្រុនចាញ់នៅឡើយ។ លើសពីនេះទៅទៀត កម្ពុជាក៏បានបង្កើតផែនការយុទ្ធសាស្ត្រជាតិលុបបំបាត់ជំងឺគ្រុនចាញ់ ឆ្នាំ២០១១-២០២៥ ដែលជាផែនទីបង្ហាញផ្លូវ និងបង្កលក្ខណៈងាយស្រួលដល់ការប្រតិបត្តិជាក់ស្តែង ឈានឆ្ពោះទៅលុបបំបាត់ជំងឺគ្រុនចាញ់ទូទាំងប្រទេស។

ចាប់តាំងពីឆ្នាំ២០១១ នៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិលុបបំបាត់ជំងឺគ្រុនចាញ់២០១១-២០២៥ របស់រាជរដ្ឋាភិបាល តាមប្រភពរបាយការណ៍ប្រចាំឆ្នាំក្នុងសេវាសុខាភិបាលសាធារណៈរបស់កម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ពីឆ្នាំ២០១១-២០១៧ មានចំនួនករណីឈឺត្រូវបានកាត់បន្ថយពី ៦២ ៥៨០ករណី មកនៅត្រឹម ៣៦ ៤៥៦ករណី និងចំនួនស្លាប់បានកាត់បន្ថយពី ៩៣នាក់ មកនៅត្រឹម ១នាក់ បានន័យថា អត្រាស្លាប់ក្នុងចំណោមមនុស្ស ១០០ ០០០នាក់ បានថយចុះពី ០,៦៥នាក់ មកនៅត្រឹម ០,០០៦នាក់ ដែលជោគជ័យមុនគោលដៅគ្រោងទុក ឆ្នាំ២០១៩។

ទោះបីយ៉ាងណាក៏ដោយ ក៏យើងមិនត្រូវភ្លេចខ្លួន ស្កប់ស្កល់នឹងលទ្ធផល ដែលយើងទទួលបាននោះទេ ព្រោះថា ជំងឺគ្រុនចាញ់នៅតែជាបន្ទុកដ៏ធ្ងន់មួយរបស់កម្ពុជា ហើយបើយើងមិនទាន់លុបបំបាត់មេរោគគ្រុនចាញ់ឱ្យអស់ពីក្នុងខ្លួនមនុស្សគ្រប់ៗរូបទេនោះ សត្វមូសដែកគោលញីដែលបន្តមាននៅក្នុងព្រៃ និងតំបន់ជុំវិញ នៅតែមានឱកាសបឺតឈាមចម្លងមេរោគគ្រុនចាញ់ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ និងពីសហគមន៍មួយទៅសហគមន៍មួយដដែល។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលតែងបានផ្តល់លទ្ធភាព និងលើកទឹកចិត្តឱ្យមានចលនាកៀរគរប្រមូលប្រភពធនធានដើម្បីជំរុញការងារប្រយុទ្ធនឹងជំងឺគ្រុនចាញ់ឱ្យកាន់តែមានសកម្មភាពខ្លាំងក្លាថែមទៀត ឆ្ពោះទៅលុបបំបាត់ជំងឺនេះឱ្យបានតាមផែនការកំណត់។ ដូច្នេះ យើងត្រូវយកចិត្តទុកដាក់ខ្ពស់ទាំងអស់គ្នាលើចំណុចទាំងនេះ ដើម្បីលើកកម្ពស់សុខភាព គុណភាពនៃការរស់នៅ និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋយើង ឱ្យសមស្របទៅនឹងតម្លៃប្រទេសជាតិ ដែលកំពុងមានអំណោយផលនូវសុខសន្តិភាព ស្ថេរភាពនយោបាយ និងវឌ្ឍនភាពសង្គម។

ក្នុងនាមរាជរដ្ឋាភិបាល និងខ្លួនខ្ញុំព្រះករុណាផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិកសុខាភិបាល រួមទាំងភាគីពាក់ព័ន្ធទាំងអស់ ទាំងក្នុងនិងក្រៅប្រទេស និងប្រជាជនគ្រប់រូប ដែលបានធ្វើឱ្យសម្រេចជោគជ័យនូវសមិទ្ធផលលើការងារប្រយុទ្ធនឹងជំងឺគ្រុនចាញ់នាពេលកន្លងមក និងសូមសម្តែងនូវការគាំទ្រយ៉ាងពេញទំហឹង ដល់សកម្មភាពប្រយុទ្ធនឹងជំងឺគ្រុនចាញ់ក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាទូទាំងសកលលោក។ ទន្ទឹមនឹងនេះ ខ្ញុំសូមអំពាវនាវឱ្យក្រសួង ស្ថាប័ន អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ទាំងអស់ វិស័យឯកជន អង្គការនានា ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន សហគមន៍ជាតិ-អន្តរជាតិ និងដៃគូអភិវឌ្ឍ ជាពិសេសប្រជាជនគ្រប់រូប សូមបន្តចូលរួមនិងគាំទ្រដល់បេសកកម្មរបស់ក្រសួងសុខាភិបាល ក្នុងការលុបបំបាត់ជំងឺគ្រុនចាញ់ក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យទទួលបានជោគជ័យ និងសម្រេចតាមគោលដៅយុទ្ធសាស្ត្រជាតិលុបបំបាត់ជំងឺគ្រុនចាញ់ឆ្នាំ២០២៥។

មុននឹងបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំ សូមឧទ្ទិសឱ្យខ្លឹមសារ និងអត្ថន័យនៃទិវាគ្រុនចាញ់ពិភពលោក ២៥ មេសា ២០១៨ ដែលមានពាក្យស្លោកថា " **ត្រៀមរួចជាស្រេច ចូលរួមលុបបំបាត់ជំងឺគ្រុនចាញ់** " ក្លាយទៅជាការអនុវត្តជាក់ស្តែង កាន់តែស៊ីជម្រៅ កាន់តែទូលំទូលាយ និងគ្រប់ជ្រុងជ្រោយ ដើម្បីឱ្យព្រះរាជាណាចក្រកម្ពុជាយើង អាចធ្វើដំណើរឆ្ពោះទៅកាន់អនាគតមួយដែលគ្មានជំងឺគ្រុនចាញ់។ តាមរយៈនេះ ខ្ញុំព្រះករុណាខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ភាគីពាក់ព័ន្ធទាំងអស់ ទាំងក្នុងជួររាជរដ្ឋាភិបាល វិស័យឯកជន អង្គការជាតិ-អន្តរជាតិ

ដៃគូអភិវឌ្ឍ សប្បុរសជន ព្រះសង្ឃ ប្រជាពលរដ្ឋទាំងអស់នឹងបន្តរួមចំណែកចូលរួម និងគាំទ្រដល់ការលើកកម្ពស់ការលុបបំបាត់ជំងឺគ្រុនចាញ់ ក្នុងបុព្វហេតុរួមចំណែកលើកកម្ពស់ថែមទៀតនូវឧត្តមភាព និងកិត្យានុភាពកម្ពុជា។

ជាទីបញ្ចប់ ជាមួយនឹងឱកាសនៃការប្រារព្ធទិវាជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ និងទិវាគ្រុនចាញ់ពិភពលោក ខ្ញុំព្រះករុណាខ្ញុំ សូមប្រគេនពរដល់ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងជូនពរឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្ស និងបងប្អូនជនរួមជាតិទាំងអស់ សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃពុធ ១១រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**